**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ ៧៩៤៧ អយក.ប្រក

# ប្រ កា ស

## ស្តីពីការបើកអនុវិទ្យាល័យ ស្រែរនោង ស្ថិតនៅក្នុងឃុំស្រែរនោង ស្រុកត្រាំកក់ ខេត្តតាកែវ

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ពទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំស្រែរនោង ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០២ ដោយមានយោបល់ឯកភាពពី មន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្តតាកែវ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

**ស ម្រេ ច**

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថាៈ អនុវិទ្យាល័យ « ស្រែរនោង »ស្ថិតនៅក្នុងឃុំស្រែរនោង ស្រុកត្រាំកក់ ខេត្តតាកែវ ចាប់ពីឆ្នាំសិក្សា ២០០២_២០០៣ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ និងនាយកអនុវិទ្យាល័យសាមីមាន ភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០២

**ស.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម_សិទ្ធី**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តតាកែវ " ដើម្បីជាពត៌មាន "
- ដូចប្រការ ៤
- កាលប្បវត្តិ_ឯកសារ ឆា.មចទ